# បម្រុងប្រយ័ត្នចំពោះការសម្អាតនិងដកបំពង់បូម

## (1) បម្រុងប្រយ័ត្នចំពោះការសម្អាតបំពង់បញ្ជូន

មានវិធីសាស្ត្រចំនួនពីរក្នុងការសម្អាតបំពង់បញ្ជូន៖ សម្អាតដោយប្រើទឹកនិងសម្អាតដោយប្រើខ្យល់។ ទោះជាយ៉ាងណាក្ដី គួរតែប្រើវិធីសាស្ត្រលាងសម្អាតដោយទឹកពីព្រោះវិធីសាស្ត្រសម្អាតដោយខ្យល់អាចបណ្ដាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដោយសារតែបន្ទុះខ្យល់។




ឧទាហរណ៍អំពីគ្រោះថ្នាក់ដោយសារបន្ទុះសម្ពាធខ្យល់នៅអំឡុងពេលសម្អាតដោយប្រើខ្យល់

## (2) នៅពេលសម្អាតបំពង់បញ្ជូន ចូរដោះចុងបំពង់ចេញ

នៅពេលសម្អាតបំពង់បញ្ជូន ដើម្បីសុវត្ថិភាព ចូរដោះចុងបំពង់ចេញ, ភ្ជាប់ប្រដាប់ទប់អង្គសម្អាត ហើយរឹតវាឲ្យជាប់ទៅនឹងកន្លែងរឹងមាំដោយប្រើខ្សែលួសឬច្រវាក់។



ការដោះចុងទុយោចេញនិងដំឡើងគ្រឿងទទួលប្រដាប់សម្អាត



ឧទាហរណ៍អំពីគ្រឿងទទួលប្រដាប់សម្អាត

## ( 3 ) ហាមប្រើបំពង់ហើយនៅចុងបំពង់បញ្ជូន។

ហាមប្រើទុយោហើយ ( ទុយោកោង ) នៅចុងបំពង់បញ្ជូនដើម្បីសម្អាត។ ប្រសិនបើប្រើទុយោហើយ, បំពង់បញ្ជូនអាចផ្ទុះដោយសារតែប្រែដាប់សម្អាតបំពង់បញ្ជូនបុកចេញក្រៅចុងទុយោ។



ឧទាហរណ៍អំពីគ្រោះថ្នាក់ដោយសារតែប្រើទុយោហើយនៅចុងបំពង់បញ្ជូន

## (4) បម្រុងប្រយ័ត្ននៅពេលសម្អាតជីឡៅ

ជានិច្ចកាល ចូរសម្អាតជីឡៅបន្ទាប់ពីបញ្ឈប់ធុងក្រឡុក (ផ្លែធុងក្រឡុក)។ ប្រសិនបើមិនបញ្ឈប់ធុងក្រឡុកទេ ដៃនិងជើងរបស់អ្នកអាចទាក់ជាប់នឹងធុងក្រឡុក ដែលអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរឬស្លាប់។





ឧទាហរណ៍អំពីគ្រោះថ្នាក់ទាក់ជាប់នឹងធុងក្រឡុកជីឡៅ

## (5) ឧបករណ៍បញ្ឈប់ក្នុងគ្រាអាសន្ន

ឧបករណ៍បញ្ឈប់គ្រាអាសន្ន (ផ្លែធុងក្រឡុក) ភ្ជាប់ទៅនឹងចំហៀងដែលអាចបញ្ឈប់ប្រតិបត្តិការបូមបេតុងដោយចុចប៊ូតុងនៅពេលមានមនុស្សទាក់ជាប់នឹងធុងក្រឡុក ឬនៅពេលវាហៀបនឹងកើតឡើង។
មានឧបករណ៍មួយស្ថិតនៅចំហៀង (គែម) ជីឡៅដែលបញ្ឈប់ធុងក្រឡុកដោយស្វ័យប្រវត្តិ ដើម្បីបង្ការគ្រោះថ្នាក់ដល់មនុស្សនៅក្នុងធុងក្រឡុក, ឧបករណ៍នោះអាចមើលឃើញនៅពេលបើកអេក្រង់ជីឡៅ។



ឧទាហរណ៍អំពីឧបករណ៍បញ្ឈប់ក្នុងគ្រាអាសន្ន



ឧទាហរណ៍អំពីឧបករណ៍បញ្ឈប់ស្វ័យប្រវត្តិ

## (6) បម្រុងប្រយ័ត្ននៅពេលសម្អាតស៊ីឡាំង

នៅពេលសម្អាតវ៉ាល់បេតុង ការសម្អាតស៊ីឡាំងត្រូវធ្វើឡើងបន្ទាប់ពីពន្លត់ម៉ាស៊ីន និងដោះប្រអប់បញ្ជាពីចម្ងាយចេញពីខ្លួនរបស់អ្នកដើម្បីបង្ការគ្រោះថ្នាក់ដោយសារតែកំហុសមុខងារ។
លើសពីនេះទៀត ហាមដាក់ដៃក្នុងស៊ីឡាំងបេតុងនៅលើរថយន្តបូមបេតុងប្រភេទពីស្តុង។ មានគ្រោះថ្នាក់ដែលបណ្តាលឲ្យវ៉ាល់បំពេញមុខងារខុសប្រក្រតីនៅពេលដាក់ដៃចូល ដែលនាំឲ្យមានរបួសធ្ងន់ធ្ងរដល់ដៃឬម្រាមដៃដែលជាប់ក្នុងឧបករណ៍វ៉ាល់នោះ។
ហាមដាក់ដៃចូលទៅក្នុងស៊ីឡាំងបេតុង។
ចូរប្រើរបារចូកនិងទឹកសម្ពាធខ្ពស់ដើម្បីបាញ់លាង វិញ។



ឧទាហរណ៍អំពីគ្រោះថ្នាក់ដែលម្រាមដៃទាក់ជាប់ក្នុងវ៉ាល់
ដែលដំណើរការអំឡុងពេលសម្អាតស៊ីឡាំង

## (7) បម្រុងប្រយ័ត្ននៅពេលបំពេញការងារនៅលើរថយន្តក្រឡុកបេតុង

នៅពេលបញ្ចូលស៊ីម៉ងត៍ដែលនៅសល់ទៅក្នុងឡានលាយ (ឡានក្រឡុក) វិញ ខណៈដែលកំពុងលាងសម្អាត, អ្នកត្រូវតែប្រើគ្រឿងបរិក្ខារបង្ការការធ្លាក់ក្រែងលោមានគ្រោះថ្នាក់ធ្លាក់ពីលើរថយន្តនៅពេលឡើងលើជីឡៅ (ប្រកចាក់បញ្ចូល) នៃរថយន្ត។



ឧទាហរណ៍អំពីគ្រោះថ្នាក់ធ្លាក់ពីធុងក្រឡុករបស់រថយន្ត

## (8) ពិនិត្យទុយោបង្ហូររបស់រថយន្តបូមបេតុង

ទីកន្លែងទាំងឡាយដែលមានសម្ភារច្រើន
ដូចជាការដ្ឋានគម្រោងនិងកន្លែងចតរថយន្តរបស់ក្រុមហ៊ុន
ចូរយកចិត្តទុកដាក់ចំពោះខ្សែចរាចរណ៍
របស់រថយន្តបូមបេតុងនៅក្នុងកន្លែងដែលមានឧបសគ្គច្រើន
មើលមិនសូវឃើញច្បាស់ និងកន្លែង
ចង្អៀត ដើម្បីបង្ការគ្រោះថ្នាក់ចរាចរណ៍។



ឧទាហរណ៍អំពីគ្រោះថ្នាក់ចរាចរណ៍បង្កឡើងដោយដោយរថយន្តបូមបេតុងនៅកន្លែងចតរថយន្តរបស់ក្រុមហ៊ុន



2020.3